Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## អ៊ី-ខូឡៃ [E. COLI]

**តើ អ៊ី-ខូឡៃ 0157:H7 គឺជាអ្វី?**

អ៊ី-ខូឡៃ 0157:H7 គឺជាបាក់តេរីពោះវៀនដ៏ពិសេសមួយប្រភេទ ដែលបង្កើតជាតិពុលដ៏ខ្លាំងមួយ អាចបង្កជម្ងឺយ៉ាងធ្ងន់ក្នុងមនុស្ស ។

**តើ អ៊ី-ខូឡៃ 0157:H7 ត្រូវបានឆ្លងយ៉ាងដូចម្តេច?**

អ៊ី-ខូឡៃ 0157:H7 អាចឆ្លងបានតាមរបៀបទាំងឡាយខាងក្រោមនេះ:

- បរិភោគអាហារដែលត្រូវបានពុលនឹងមេរោគ នៅពេលដែលសម្លាប់សត្វ
- បរិភោគសាច់ ឬស៊ុត ដ៏ឆៅ ឬស្ទើរឆ្អិន ជាពិសេសសាច់គោ
- បរិភោគបន្លែមិនស្អាត ដូចជាបណ្តុះ ឬសាលាត
- ផឹកទឹកដោះគោ ឬទឹកផ្លែឈើឆៅ
- ផឹកទឹកមិនស្អាត
- ហែលទឹកលេង ក្នុងទឹកមិនស្អាត
- មិនលាងដៃ ក្រោយពីបត់ជើង ឬដូរកន្ទបក្មេង

**តើមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញានៃអ៊ី-ខូឡៃ 0157:H7  អាចមានរួមទាំង:

- ជម្ងឺរាគ មានឈាម
- រមួលចុកពោះ

យូរៗ ម្តង រោគនេះគ្មានរោគសញ្ញាសោះ ។

*មនុស្សចាស់ និងកូនក្មេងក្រោមអាយុ 5 ឆ្នាំ ចំនួន 2% ទៅ 7% ដែលឆ្លងមេរោគ អ៊ី-ខូឡៃ 0157:H7 កើតជម្ងឺមួយ ហៅថា ហ៊ីម៉ូលិទិក យូរីមិក ស៊ិនដ្រូម (HUS) ដែលក្នុងនោះ កោសិកាឈាមក្រហមត្រូវបានបំផ្លាញ ហើយតំរងនោមឈប់ដើរ ។*

**រោគសញ្ញា HUS អាចមានរួមទាំង:**

- លើសឈាម
- ប្រកាច់ប្រកិន
- ងងឹតភ្នែក
- ខ្វិន

**តើអ៊ី-ខូឡៃ 0157:H7 ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**

ធម្មតា អ៊ី-ខូឡៃ 0157:H7 ត្រូវបានវិនិច្ឆ័យរោគ តាមរយៈការពិនិត្យលាមក ។ អ្នកណាដែលមានឈាមនៅក្នុងលាមករបស់គេ គួរតែឱ្យពេទ្យពិនិត្យលាមក ។ ការពិនិត្យលាមកបន្តបន្ទាប់ទៀតអាចជួយឱ្យដឹងពេលដែលមេរោគអស់ពីខ្លួនហើយ ។

**តើអ៊ី-ខូឡៃ 0157:H7 ត្រូវបានព្យាបាលយ៉ាងដូចម្តេច?**

អ៊ី-ខូឡៃ 0157:H7 គ្មានវិធីព្យាបាលជាក់លាក់ទេ ហើយធម្មតា វាជាដោយខ្លួនវា ក្នុងរយះពេល 5-10 ថ្ងៃ ។ អ្នកដែលមានរោគនេះត្រូវផឹកទឹកឱ្យបានច្រើន ។ ថ្នាំរាគ ដូចជា *Imodium* និង *Lomotil* ***គឺមិនត្រូវប្រើទេ ។***

**តើអាចបង្ការអ៊ី-ខូឡៃ 0157:H7 បានយ៉ាងដូចម្តេច?**

- ចំអិនសាច់គោកិនឱ្យបានឆ្អិនទាំងស្រុង (កំដៅនៅក្នុងសាច់ត្រូវតែឡើងដល់ 155° F សម្រាប់រយះពេលយ៉ាងហោចណាស់ 15 វិនាទី)
- រៀបចំសាច់ និងស៊ុត ឱ្យឆ្ងាយពីអាហារផ្សេងទៀត
- លាងដៃក្រោយពីប៉ះពាល់សាច់
- លាងតុចង្ក្រានបាយដោយទឹកក្តៅ និងសាប៊ូ ក្រោយពីវាប៉ះសាច់ ឬស៊ុតឆៅ
- ផឹកតែទឹកដោះគោ និងទឹកផ្លែឈើ ដែលត្រូវបានកំដៅសម្លាប់មេរោគប៉ុណ្ណោះ
- លាងផ្លែឈើ និងបន្លែ ឱ្យបានប្រុងប្រយ័ត្ន
- ចៀសវាងកុំឱ្យផឹកទឹកបឹង ឬទឹកអាង នៅពេលហែលទឹកលេង
- លាងដៃដោយសាប៊ូ ក្រោយពីបត់ជើង ដូរកន្ទបក្មេង និងមុនរៀបចំអាហារ និងភេសជ្ជះ

**សម្រាប់ព័ត៌មានអំពីអ៊ី-ខូឡៃ 0157:H7 ទាក់ទង:**

Ottawa County Health Department
www.miOttawa.org

Center for Disease Control and Prevention
www.bt.cdc.gov/
ទូរស័ព្ទ: (888) 246-2675

12251 James St., Suite 400
Holland, MI  49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ:  (616) 393-5643
វ៉ិបសាយ: www.miOttawa.org